ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ២៧៨៧៣ ប្រ.ក

# ប្រកាស
## ស្តីពី
## តួនាទីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធ
## របស់នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច

៣៣ * ៤៤

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពីការប្តូរឈ្មោះនាយកដ្ឋាននគរបាលសេដ្ឋកិច្ច មកជានាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់អគ្គស្នងការនគរបាលជាតិ

## ស ម្រេ ច

**ប្រការ១:** នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ជាអង្គភាពជំនាញស្ថិតក្រោមការគ្រប់គ្រងដឹកនាំរបស់នាយកដ្ឋានកណ្តាល-នគរបាលយុត្តិធម៌ មានតួនាទីជាសេនាធិការជូននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ក្នុងកិច្ចប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេត បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងបទល្មើសសេដ្ឋកិច្ចគ្រប់ប្រភេទ ដើម្បីរួមចំណែកអភិវឌ្ឍន៍ និងការពារគោលនយោបាយសេដ្ឋកិច្ចជាតិរបស់រាជរដ្ឋាភិបាល ។

ប្រការ២: នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច មានភារកិច្ច និងសិទ្ធិដូចតទៅ :

ក-អំពីភារកិច្ច:

១- សិក្សាស្វែងយល់អំពីច្បាប់ ក្តាប់បានអំពីយុទ្ធសាស្ត្រ គោលការណ៍ គោលនយោបាយសេដ្ឋកិច្ច បទកំណត់ បទដ្ឋាននានារបស់រាជរដ្ឋាភិបាល និងធ្វើការប្រមូលផ្តុំព័ត៌មាន សភាពការណ៍បាតុភាពសេដ្ឋកិច្ចទាំងក្នុងប្រទេស និងអន្តរជាតិ ព្រមទាំងធ្វើការប្រមូលផ្តុំព័ត៌មាន ស្តីពីសកម្មភាពបទល្មើសសេដ្ឋកិច្ចដើម្បី :

- វិភាគវាយតម្លៃ និងផ្តើមស្នើគោលការណ៍ លើកផែនការជូនអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ពិនិត្យសម្រេចដាក់ចេញវិធានការប្រតិបត្តិការស្រាវជ្រាវ បង្ការ និងប្រឆាំងបទល្មើសសេដ្ឋកិច្ច ។

- វិភាគ វាយតម្លៃសភាពការណ៍ ស្វែងរកមូលហេតុ ឬបាតុភាពទាំងឡាយណាដែលមានឥទ្ធិពលអវិជ្ជមានចំពោះស្ថានភាពសេដ្ឋកិច្ចជាតិ និងពិចារណាផ្តួចផ្តើមលើកឡើងនូវគោលគំនិត ឬទស្សនវិស័យជូនអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដើម្បីចូលរួមយោបល់បំពេញបន្ថែមលើគោលនយោបាយសេដ្ឋកិច្ច គោលការណ៍ បទកំណត់ បទដ្ឋាននានាជូនរាជរដ្ឋាភិបាល ។

- តាមដាន ត្រួតពិនិត្យរាល់សកម្មភាពនៃការអនុវត្តន៍ច្បាប់ គោលនយោបាយ បទកំណត់ និងបទដ្ឋាននានារបស់រាជរដ្ឋាភិបាល សំដៅក្តាប់ឱ្យបានអំពីល្បិចកល ឬមូលហេតុដែលបង្កើតឱ្យមានបទល្មើសសេដ្ឋកិច្ចលើកយោបល់ជូនអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ដាក់ចេញវិធានការប្រយុទ្ធប្រឆាំងបទល្មើសសេដ្ឋកិច្ច ឬលើកសំណើទៅសាមីស្ថាប័ននីតិបុគ្គលសាធារណៈ ដើម្បីរួមសហការក្នុងការ បង្ការទប់ស្កាត់ ប្រឆាំងទៅនឹងការបំពារបំពាន ឬបទល្មើសទាន់ពេលវេលា និងចូលរួមចំណែកក្នុងការប្រឆាំងអំពើពុករលួយ ។

- ធ្វើការសិក្សាឯកទេសជំនាញតាមបែបវិទ្យាសាស្ត្រ បម្រើឱ្យការស្រាវជ្រាវ បង្ការ ប្រឆាំងបទល្មើសសេដ្ឋកិច្ច និងប្រជុំដកពិសោធន៍ កែលម្អលើកកម្ពស់ប្រសិទ្ធភាពកិច្ចប្រតិបត្តិការ និងការងារដឹកនាំស្របតាមដំណាក់កាលនៃសភាពការវិវត្តថ្មី ។

២- សហការជាមួយស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ស្រាវជ្រាវ ស៊ើបអង្កេត បង្ការ រាល់បាតុភាពបទល្មើសសេដ្ឋកិច្ចគ្រប់ប្រភេទ ដើម្បីចូលរួមធានាស្ថេរភាពនៃស្ថាប័នសេដ្ឋកិច្ច ការពារធនធានធម្មជាតិ បរិស្ថាន ការពារផលប្រយោជន៍ និងសិទ្ធិស្របច្បាប់នៃការប្រកួតប្រជែងនៅលើទីផ្សារ ការពារកម្មសិទ្ធិបញ្ញា និងសិទ្ធិផលិត ការពារផលប្រយោជន៍ និងសុខុមាលភាពអ្នកប្រើប្រាស់ ធានាគុណភាព និងធានាស្ថេរភាពផលិតកម្ម ។

៣- ស្រាវជ្រាវ ស៊ើបអង្កេតរាល់សកម្មភាពពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម ផលិតកម្ម វិស្វកម្ម ស្ថាបត្យកម្ម វិនិយោគលើគ្រប់វិស័យរបស់ស្ថាប័ននីតិបុគ្គលឯកជន សំដៅស្វែងរក និងកំណត់ឱ្យបានច្បាស់លាស់នូវគោលដៅមុខសញ្ញាប្រព្រឹត្តបទល្មើសសេដ្ឋកិច្ច ដើម្បីស្នើសុំគោលការណ៍អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ពិនិត្យសម្រេចដាក់ចេញវិធានការស្រាវជ្រាវ ស៊ើបអង្កេត និងតស៊ូប្រឆាំង ។

៤- តាមដាន និងពិចារណា វាយតម្លៃ រាល់ការវិវត្តន៍ប្រែប្រួលនៃសភាពការណ៍បទល្មើសសេដ្ឋកិច្ចដើម្បីធ្វើការ ព្យាករណ៍កំណត់លើកផែនការយុទ្ធសាស្ត្រ បម្រើឱ្យកិច្ចប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេតប្រឆាំងបទល្មើសសេដ្ឋកិច្ចគ្រប់ប្រភេទតាមដំណាក់កាលនីមួយៗ ជាពិសេសសិក្សាស្រាវជ្រាវ ស្វែងយល់ និងលើកវិធានការតស៊ូប្រឆាំងទៅនឹងបទល្មើសសេដ្ឋកិច្ច តាមបែបបច្ចេកវិទ្យា ។

៥- តាមដាន វិភាគវាយតម្លៃ និងធ្វើការស្រាវជាវ ស្វែងរកសកម្មភាពបទល្មើសសេដ្ឋកិច្ចដែលមានខ្សែរយៈចាក់តែងជាអន្តរជាតិ និងបទល្មើសទាំងឡាយណាដែលមានលក្ខណៈស្មុគស្មាញធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់គោលនយោបាយ សេដ្ឋកិច្ចជាតិ និងច្បាប់រដ្ឋ ឬក៏មានឥទ្ធិពលអវិជ្ជមានដល់សន្តិសុខសេដ្ឋកិច្ចជាតិ ព្រមទាំងបណ្តាសកម្មភាពដែលមានចរិតលក្ខណៈវិទ្ធង្សនា ឬជាវិច្ឆេទកម្មសេដ្ឋកិច្ច ដើម្បីស្នើសុំគោលការណ៍អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃមានវិធានការបានទាន់ពេលវេលា ។

៦- ចាត់តាំងចង្អុលដឹកនាំ ត្រួតពិនិត្យ ណែនាំដល់អង្គភាពពាក់ព័ន្ធក្រោមឱវាទ ដើម្បីជម្រុញឱ្យមានដំណើរការស្រាវជ្រាវ ស៊ើបអង្កេត បង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងបទល្មើសសេដ្ឋកិច្ចទៅតាមនីតិវិធីក្នុងដែនសមត្ថកិច្ចជានគរបាលយុត្តិធម៌ ។

៧- ទំនាក់ទំនងជាមួយព្រះរាជអាជ្ញា តុលាការក្នុងការអនុវត្តន៍នីតិវិធីប្រតិបត្តិការ សំដៅធានាដល់ការបង្ក្រាបបទល្មើស-សេដ្ឋកិច្ចក្នុងប្រទេសឱ្យទទួលបានលទ្ធផលល្អប្រសើរ និងអនុវត្តដីកា សាលក្រម សាលដីកានានារបស់តុលាការ ។

៨- កសាងផែនការបណ្តុះបណ្តាល និងវិក្រឹតការដល់មន្ត្រីក្រោមឱវាទនាយកដ្ឋាន ទាំងមុខជំនាញ ច្បាប់ ភាសាបរទេស តាមសំណូមពរនៃការងារ ។

៩- ធ្វើរបាយការណ៍បូកសរុបសភាពការណ៍ និងលទ្ធផលការងារជូននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ និងអគ្គស្នងការដ្ឋាននគរបាលជាតិតាមការកំណត់ ។

១០- ធ្វើការងាររដ្ឋបាល បុគ្គលិក ភស្តុភារ គណនេយ្យរបស់នាយកដ្ឋាន ។

១១- បំពេញភារកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួង-មហាផ្ទៃប្រគល់ឱ្យ ។

ខ-អំពីសិទ្ធិ:

១-ចាត់តាំងគ្រប់គ្រង បញ្ជា ដឹកនាំមន្ត្រីនគរបាលក្រោមឱវាទនាយកដ្ឋាន បំពេញប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេត បង្ការទប់ស្កាត់ និងប្រឆាំងបទល្មើសសេដ្ឋកិច្ចគ្រប់ប្រភេទ ។

២-កសាង គ្រប់គ្រងភ្នាក់ងារផ្តល់ព័ត៌មាន សំដៅស្រាវជ្រាវរកឱ្យឃើញល្បិចកល ឫសគល់នៃសកម្មភាព បទល្មើសវិច្ឆេទកម្ម និងវិទ្ធង្សនាសេដ្ឋកិច្ច ព្រមទាំងធ្វើទំនាក់ទំនងគ្រប់អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីប្រមូលផ្តុំព័ត៌មានបាតុភាពសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស ស្របតាមការកំណត់របស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួង-មហាផ្ទៃ ។

៣-ធ្វើសេនាធិការជូនអគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងការតាមដានត្រួតពិនិត្យ ណែនាំមុខជំនាញដល់នគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចរាជធានី-ខេត្ត អំពីការអនុវត្តន៍ច្បាប់ បទកំណត់ បទដ្ឋាន និងវិធានការជំនាញនានាដែលពាក់ព័ន្ធដល់ការងារស្រាវជ្រាវ ស៊ើបអង្កេត បង្ការ ទប់ស្កាត់ និង ប្រឆាំងបទល្មើសសេដ្ឋកិច្ច ។

៤-ប្រមែប្រមូលឯកសារ និងភស្តុតាង ដាក់បន្ទុកបទល្មើស ដើម្បីកសាងសំណុំរឿងតាមនីតិវិធីបញ្ជូនទៅតុលាការ នូវរាល់បទល្មើសសេដ្ឋកិច្ចក្នុងដែនសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ ។

៥-ពិនិត្យវាយតម្លៃ ដាក់ពិន្ទុ មូលវិចារណ៍ ដើម្បីស្នើតែងតាំងតម្លើងឋានៈ ឋានន្តរសក្តិ ផ្ទេរផ្លាស់ប្តូរភារកិច្ច លើក-សរសើរជូនរង្វាន់ ឬដាក់វិន័យ ដកហូតមុខតំណែង ឋានន្តរសក្តិ មន្ត្រីនគរបាលជាតិក្រោមឱវាទនាយកដ្ឋានតាមការបែងចែកថ្នាក់គ្រប់គ្រងរបស់ក្រសួង និងតាមលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ។

ប្រការ ៣ : នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចដឹកនាំដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនជាជំនួយ ។

ប្រការ ៤ : រចនាសម្ព័ន្ធរបស់នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចមាន :

១- ការិយាល័យរដ្ឋបាល-សរុប ហៅកាត់ថា( ក$_{១}$)

២- ការិយាល័យការពារសន្តិសុខសេដ្ឋកិច្ចជាតិ ហៅកាត់ថា( ក$_{២}$)

៣- ការិយាល័យប្រឆាំងបទល្មើសកម្មសិទ្ធិបញ្ញា ហៅកាត់ថា( ក$_{៣}$)

៤- ការិយាល័យប្រឆាំងបទល្មើសអាជីវកម្ម សេវាកម្ម និងផលិតកម្ម ហៅកាត់ថា( ក$_{៤}$)

៥- ការិយាល័យប្រឆាំងបទល្មើសគេចពន្ធ និងសារពើពន្ធ ហៅកាត់ថា( ក$_{៥}$)

៦- ការិយាល័យប្រឆាំងបទល្មើសវិស្វកម្ម ស្ថាបត្យកម្ម និងវិនិយោគ ហៅកាត់ថា( ក$_{៦}$)

៧- ការិយាល័យការពារតម្លៃ បរិមាណ និងគុណភាព ហៅកាត់ថា( ក$_{៧}$)

៨- ការិយាល័យការពារធនធានធម្មជាតិ បរិស្ថាន និងសុខុមាលភាព ហៅកាត់ថា( ក$_{៨}$)

ប្រការ ៥ : ការិយាល័យចំណុះនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចមានភារកិច្ចដូចខាងក្រោម :

**៥-១. ការិយាល័យរដ្ឋបាល-សរុប (ក១) មានភារកិច្ច :**

- ធ្វើសេនាធិការជូនប្រធាននាយកដ្ឋាន លើការងារទទួល និងបញ្ជូនបញ្ជារបស់ប្រធាននាយកដ្ឋានឱ្យទៅការិយាល័យនានាក្រោមឱវាទនាយកដ្ឋាន ។
- រៀបចំកម្មវិធី ផែនការសកម្មភាព និងទិសដៅរបស់នាយកដ្ឋាន ។
- ធ្វើការងាររបៀបរដ្ឋបាល ទទួលចុះបញ្ជី និងចរាចរលិខិតទៅតាមជំនាញឱ្យបានត្រឹមត្រូវតាមការកំណត់ ។
- រៀបចំការងារប្រជុំ ទីកន្លែងប្រជុំ កន្លែងធ្វើការ ទទួលភ្ញៀវ និងការងារអនាម័យរបស់នាយកដ្ឋាន ។
- រៀបចំចងក្រងទុកដាក់ និងថែរក្សាឯកសារទៅតាមលក្ខការណ៍បច្ចេកទេស និងបោះពុម្ព ថតចម្លង ធ្វើការផ្សព្វផ្សាយគោលការណ៍ ផែនការ វិធានការ បទបញ្ជា សារាចរណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ។
- សិក្សាស្រាវជ្រាវ រៀបចំកសាងលិខិតបទដ្ឋាន បទបញ្ជាផ្ទៃក្នុង របៀបរបបការងារ ដើម្បីលើកយោបល់ជូនប្រធាននាយកដ្ឋានពិនិត្យសម្រេច ។
- តាមដាន ត្រួតពិនិត្យ វាយតម្លៃសកម្មភាពនៃបណ្តាអង្គភាពជំនាញ នគរបាលស្រាវជ្រាវ ប្រឆាំងបទល្មើសសេដ្ឋកិច្ចទូទាំងប្រទេស និងលើកវិធានការពង្រឹងជំនាញតាមខ្សែបណ្តោយ ។
- ធ្វើការពិចារណា វិភាគសភាពការណ៍ សកម្មភាពបទល្មើសសេដ្ឋកិច្ច និងបូកសរុបរបាយការណ៍ ធ្វើការសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងាររបស់នាយកដ្ឋាន ជូននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ និងអគ្គស្នងការដ្ឋាននគរបាលជាតិ តាមការកំណត់ ។
- ធ្វើការងារបុគ្គលិក ភស្តុភារ គណនេយ្យរបស់នាយកដ្ឋានតាមការកំណត់ ។
- គ្រប់គ្រងចលនៈ និងអចលនទ្រព្យរបស់នាយកដ្ឋាន ។
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ ។

**៥-២. ការិយាល័យការពារ សន្តិសុខសេដ្ឋកិច្ចជាតិ (ក២) មានភារកិច្ច :**

- ធ្វើសេនាធិការជូនប្រធាននាយកដ្ឋាន ក្នុងការលើកផែនការ វិធានការស្រាវជ្រាវ បង្ការប្រឆាំងនឹងបទល្មើសសេដ្ឋកិច្ចគ្រប់ប្រភេទមានចរិតលក្ខណៈជាវិច្ឆេទកម្ម ឬវិទ្ធង្សនាសេដ្ឋកិច្ច ដែលរារាំងដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ គិតទាំងសកម្មភាពអាជីវកម្ម សេវាកម្ម វិនិយោគលើវិស័យធនាគារ ហិរញ្ញវត្ថុ ការផលិត និងចរាចររូបិយប័ណ្ណ រូបិយវត្ថុក្លែងក្លាយ ការក្លែងបន្លំប័ណ្ណឥណទាន និងការលួចលេខគណនេយ្យបង្វែរប្រាក់តាមបែបបច្ចេកវិទ្យាជាន់ខ្ពស់ និងការលាងលុយកខ្វក់ ។ល។ សំដៅការពារកំណើនសេដ្ឋកិច្ចជាតិ និងការពារគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីរួមចំណែកធានាស្ថេរភាព និរន្តរភាពម៉ាក្រូសេដ្ឋកិច្ច និងជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។
- ធ្វើសេនាធិការជូនថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ក្នុងការវិភាគ វាយតម្លៃ ព្យាករណ៍អំពីបាតុភាពសេដ្ឋកិច្ច សកម្មភាពដែលមានឥទ្ធិពលអវិជ្ជមាន អាចធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចជាតិ ឬប៉ះពាល់ដល់សន្តិសុខសេដ្ឋកិច្ចជាតិ និងផ្តួចផ្តើមលើកឡើងនូវគោលការណ៍ វិធានការ ដើម្បីកែលម្អ ដោះស្រាយ បង្ការទប់ស្កាត់បណ្តាបាតុភាពទាំងនោះ ។
- ស្រាវជ្រាវ សិក្សាស្វែងយល់អំពីច្បាប់ គោលនយោបាយ បទកំណត់ បទដ្ឋាននានារបស់រាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័ននីតិបុគ្គលសាធារណៈ ក្តាប់បានអំពីការវិវត្តន៍ប្រែប្រួលសភាពការណ៍សេដ្ឋកិច្ចជាសកល និង

វិភាគវាយតម្លៃ ព្យាករណ៍នូវសកម្មភាពបទល្មើសទាំងឡាយណា ដែលមានចរិតលក្ខណៈឆ្លងដែន និងមានខ្សែរយៈចាត់តាំង សំដៅផ្តួចផ្តើមបង្កើតឡើងនូវផែនការណ៍ វិធានការជាយុទ្ធសាស្ត្រ និងស្នើសុំគោលការណ៍សម្រេចពីថ្នាក់ដឹកនាំតាមលំដាប់ថ្នាក់ ដើម្បីពិនិត្យសម្រេច ផ្តល់ការអនុញ្ញាតធ្វើប្រតិបត្តិការបង្ការទប់ស្កាត់ ប្រឆាំងបទល្មើសសេដ្ឋកិច្ចទាន់ពេលវេលា និងមានប្រសិទ្ធភាព ។

- សហការជាមួយការិយាល័យជំនាញពាក់ព័ន្ធក្រោមឱវាទនាយកដ្ឋាន ដើម្បីពិភាក្សា វាយតម្លៃ ទំហំនៃបទល្មើសសេដ្ឋកិច្ច និងប្រមូលផ្តុំឯកសារ ព័ត៌មានដែលទាក់ទិនដល់ការស្រាវជ្រាវ ស៊ើបអង្កេត និងស្នើសុំគោលការណ៍ពីថ្នាក់ដឹកនាំតាមលំដាប់ថ្នាក់ ដើម្បីដាក់ចេញនូវវិធានការតស៊ូករណី ។
- សិក្សាស្វែងយល់អំពីល្បិចកលនៃបទល្មើសសេដ្ឋកិច្ចដែលប្រើប្រាស់ជំនាញឯកទេស និងឧបករណ៍បច្ចេកវិទ្យាទំនើប ដើម្បីលើកឡើងវិធានការសហការជាមួយស្ថាប័នមានសមត្ថកិច្ច រិះរកយុទ្ធវិធីទប់ស្កាត់ និងបង្ក្រាប ។
- ចាត់តាំង តាមដាន ត្រួតពិនិត្យ បម្រើឱ្យការងារជំនាញជាមូលដ្ឋានគ្រឹះ ដូចជាការងារស្រាវជ្រាវជាមូលដ្ឋាន ការស្រាវជ្រាវករណីសង្ស័យ ការកសាងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ការប្រើប្រាស់ជំនាញស៊ើបការបច្ចេកទេស ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសសន្តិសុខសេដ្ឋកិច្ចជាតិ ។
- ប្រមូលផ្តុំឯកសារ ភស្តុតាង ដើម្បីកសាងសំណុំរឿងតាមនីតិវិធីបញ្ជូនទៅតុលាការវិនិច្ឆ័យទោស ចំពោះរូបវន្តបុគ្គល ឬស្ថាប័ននីតិបុគ្គលឯកជនណាដែលបានប្រព្រឹត្ត ឬបង្កើតឱ្យមានឥទ្ធិពលបង្កឱ្យមានប៉ះពាល់ដល់ខឿនសេដ្ឋកិច្ច ឬបង្កឱ្យមានអសន្តិសុខសេដ្ឋកិច្ច ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូននាយកដ្ឋានតាមការកំណត់ ។
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ ។

**៥-៣. ការិយាល័យប្រឆាំងបទល្មើសកម្មសិទ្ធិបញ្ញា (ក៣) មានភារកិច្ច ៖**

- ធ្វើសេនាធិការជូនប្រធាននាយកដ្ឋាន ក្នុងការពិចារណាលើកផែនការ វិធានការ ដើម្បីស្រាវជ្រាវប្រឆាំងរាល់សកម្មភាព និងល្បិចកលបទល្មើសដែលពាក់ព័ន្ធដល់ការរំលោភបំពានលើកម្មសិទ្ធិបញ្ញាគ្រប់រូបភាព ដើម្បីការពារគោលនយោបាយរបស់រាជរដ្ឋាភិបាល និងច្បាប់រដ្ឋ ព្រមទាំងការពារផលប្រយោជន៍ និងសិទ្ធិស្របច្បាប់របស់ម្ចាស់ផលិតផល ក៏ដូចជាការពារផលប្រយោជន៍ និងសុខុមាលភាពអ្នកប្រើប្រាស់ ។
- សិក្សាស្វែងយល់អំពីច្បាប់ ក្តាប់បានអំពីគោលនយោបាយ បទកំណត់ បទដ្ឋានរបស់រាជរដ្ឋាភិបាល និងប្រមូលផ្តុំព័ត៌មានស្តីពីសភាពការណ៍ដែលពាក់ព័ន្ធដល់ការរំលោភបំពានទៅនឹងច្បាប់ បទកំណត់ និងបទដ្ឋាននានា ស្តីពីកម្មសិទ្ធិបញ្ញា ដើម្បីលើកផែនការ វិធានការ តស៊ូប្រឆាំងនឹងបទល្មើសទាំងនោះ ។
- ចាត់តាំង តាមដាន ត្រួតពិនិត្យបម្រើឱ្យការងារជំនាញជាមូលដ្ឋានគ្រឹះ ដូចជាការងារស្រាវជ្រាវជាមូលដ្ឋាន ការស្រាវជ្រាវករណីសង្ស័យ ការកសាងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ការប្រើប្រាស់ជំនាញស៊ើបការបច្ចេកទេស ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសកម្មសិទ្ធិបញ្ញា ។
- ដំណើរការស្រាវជ្រាវ ស៊ើបអង្កេត កំណត់អត្តសញ្ញាណ មុខសញ្ញា និងគោលដៅសង្ស័យ ដោយសហការជាមួយស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីប្រមូលផ្តុំឯកសារ ភស្តុតាងដាក់បន្ទុកជនល្មើស និងកសាងសំណុំរឿងតាមនីតិវិធីបញ្ជូនទៅតុលាការ ដើម្បីវិនិច្ឆ័យទោសតាមច្បាប់ ។

- សហការជាមួយការិយាល័យជំនាញពាក់ព័ន្ធចំណុះនាយកដ្ឋាន ដើម្បីពិភាក្សា វាយតម្លៃលើទំហំនៃផលប៉ះពាល់ដែលកើតឡើងពីការក្លែងបន្លំ ក៏ដូចជាការរំលោភបំពានលើកម្មសិទ្ធិបញ្ញា ព្រមទាំងលើកឡើងនូវវិធានការជំនាញ បម្រើឱ្យកិច្ចសហការបង្ក្រាបករណីល្មើសទាំងនោះ ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូននាយកដ្ឋានតាមការកំណត់ ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ ។

**៥-៤. ការិយាល័យប្រឆាំងបទល្មើសអាជីវកម្ម សេវាកម្ម និងផលិតកម្ម (ក៤) មានភារកិច្ច :**

- ធ្វើជាសេនាធិការជូនប្រធាននាយកដ្ឋាន ក្នុងការលើកផែនការ វិធានការជំនាញ ដើម្បីស្រាវជ្រាវ តស៊ូករណីបង្ការទប់ស្កាត់ ប្រឆាំងបទល្មើសដែលពាក់ព័ន្ធដល់ការធ្វើអាជីវកម្ម សេវាកម្ម ផលិតកម្មគ្រប់វិស័យ (លើកលែងតែសកម្មភាពដែលពាក់ព័ន្ធដល់វិស័យការពារធនធានធម្មជាតិ បរិស្ថាន ហិរញ្ញវត្ថុ ធនាគារ វិស្វកម្ម ស្ថាបត្យកម្ម សុខាភិបាល និងវិនិយោគ) ។
- សិក្សាស្វែងយល់អំពីច្បាប់ ក្តាប់បានគោលនយោបាយរបស់រាជរដ្ឋាភិបាល បទកំណត់ បទដ្ឋានទាំងឡាយដែលពាក់ព័ន្ធដល់ការត្រួតពិនិត្យ គ្រប់គ្រងលើវិស័យសេវាកម្ម អាជីវកម្ម ផលិតកម្ម ព្រមទាំងតាមដានវិភាគវាយតម្លៃលើសកម្មភាពល្បិចកល បទល្មើសដែលមានការពាក់ព័ន្ធទៅនឹងវិស័យទាំងនោះ សម្រាប់ធ្វើជាមូលដ្ឋានពិចារណា លើកយោបល់ជូនថ្នាក់ដឹកនាំតាមលំដាប់ថ្នាក់ ដើម្បីដាក់ចេញនូវផែនការ វិធានការប្រយុទ្ធ ប្រឆាំងបទល្មើស សំដៅចូលរួមធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។
- តាមដាន ស៊ើបអង្កេតសកម្មភាពបទល្មើស ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងអាជីវកម្ម សេវាកម្ម ផលិតកម្មគ្រប់វិស័យ ស្វែងរកឱ្យឃើញនូវភាពអសកម្ម ឬភាពមិនប្រក្រតីក្នុងការអនុវត្តន៍ច្បាប់ គោលការណ៍ គោលនយោបាយ បទកំណត់ និងបទដ្ឋាននានារបស់រាជរដ្ឋាភិបាល ដើម្បីស្នើយោបល់ជូនទៅថ្នាក់ដឹកនាំតាមលំដាប់ថ្នាក់ មានវិធានការកែលម្អ ដោះស្រាយទាន់ពេលវេលានូវភាពអសកម្ម ឬភាពមិនប្រក្រតីទាំងនោះ ។
- ចាត់តាំង តាមដាន ត្រួតពិនិត្យបម្រើឱ្យការងារជំនាញជាមូលដ្ឋានគ្រឹះ ដូចជាការងារស្រាវជ្រាវជាមូលដ្ឋាន ការស្រាវជ្រាវករណីសង្ស័យ ការកសាងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ការប្រើប្រាស់ជំនាញ ស៊ើបការបច្ចេកទេស ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសពាក់ព័ន្ធដល់ការធ្វើអាជីវកម្ម សេវាកម្ម និងផលិតកម្ម ។
- ដំណើរការស្រាវជ្រាវ ស៊ើបអង្កេត កំណត់អត្តសញ្ញាណ មុខសញ្ញា និងគោលដៅសង្ស័យ ដោយសហការជាមួយស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីប្រមូលផ្តុំឯកសារ ភស្តុតាងដាក់បន្ទុកជនល្មើស និងកសាងសំណុំរឿងតាមនីតិវិធីបញ្ជូនទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់ ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូននាយកដ្ឋានតាមការកំណត់ ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ ។

**៥-៥. ការិយាល័យប្រឆាំងបទល្មើសគេចពន្ធ និងសារពើពន្ធ (ក៥) មានភារកិច្ច :**

- ធ្វើសេនាធិការជូនប្រធាននាយកដ្ឋានក្នុងការពិចារណា លើកផែនការ វិធានការ ស្រាវជ្រាវ បង្ការប្រឆាំងអំពើគេចពន្ធ ឬបន្លំពន្ធ នាំចេញ នាំចូល ការរត់ពន្ធរូបិយវត្ថុ ការលួចពន្ធអាជីវកម្ម សេវាកម្ម និងផលិតកម្មគ្រប់ប្រភេទ រួមទាំងការនាំចូលទំនិញហាមឃាត់ និងទំនិញខូចគុណភាព ឬហួសកាលបរិច្ឆេទប្រើប្រាស់ ។
- សិក្សាស្វែងយល់ អំពីច្បាប់បទដ្ឋាននៃការប្រមូលពន្ធ (ពន្ធគយ-រដ្ឋាករ និងពន្ធដារ) ក្តាប់បានអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់អត្រាពន្ធ និងក្តាប់ឱ្យបានអំពីល្បិចកលនៃអំពើរត់ពន្ធ ការលួចបន្លំ គេងប្រាក់ពន្ធ ដើម្បីពិចារណារកឃើញវិធីសាស្ត្រប្រឆាំងអំពើរត់គេច ឬបន្លំពន្ធ និងផ្តើមលើកយោបល់ជូនថ្នាក់ដឹកនាំតាមលំដាប់ថ្នាក់ មានវិធានការទាន់ពេលវេលា ។

- ចាត់តាំង តាមដាន ត្រួតពិនិត្យ បម្រើឱ្យការងារជំនាញជាមូលដ្ឋានគ្រឹះ ដូចជាការងារស្រាវជ្រាវជាមូលដ្ឋាន ការស្រាវជ្រាវករណីសង្ស័យ ការកសាងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ការប្រើប្រាស់ជំនាញស៊ើបការបច្ចេក-ទេស ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសគេចពន្ធ និងសារពើពន្ធ ។
- ប្រមែប្រមូលឯកសាររស់អិត និងធ្វើការស៊ើបបញ្ជាក់ប្រមូលផ្តុំព័ត៌មានបន្ថែម សំដៅរកឃើញបទល្មើសសេដ្ឋកិច្ច ធ្វើការកំណត់មុខសញ្ញាសង្ស័យ ដើម្បីលើកវិធានការតស៊ូបង្ក្រាប និងចងក្រងសំណុំរឿងចោទប្រកាន់តាមនីតិវិធីបញ្ជូនទៅតុលាការវិនិច្ឆ័យតាមច្បាប់ ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូននាយកដ្ឋានតាមការកំណត់ ។
- បំពេញភារកិច្ចផ្សេង១ទៀត ដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ ។

**៥-៦. ការិយាល័យប្រឆាំងបទល្មើស វិស្វកម្ម ស្ថាបត្យកម្ម និងវិនិយោគ (ក៦) មានភារកិច្ច :**

- ធ្វើសេនាធិការជូនប្រធាននាយកដ្ឋាន ក្នុងការពិចារណាលើកផែនការ វិធានការ ស្រាវជ្រាវប្រឆាំងសកម្មភ៌ាគ និងល្បិចកលបទល្មើសដែលពាក់ព័ន្ធដល់ផ្នែកវិស្វកម្ម ស្ថាបត្យកម្ម និងវិនិយោគគ្រប់វិស័យ រួមទាំងសកម្មភាពអនុវត្ត និងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ ភាពមិនប្រក្រតីចំពោះការដាក់ដេញថ្លៃ ឬប្រគល់សិទ្ធិប្រតិបត្តិការនូវគម្រោងអភិវឌ្ឍន៍ និងសំណង់វិស្វកម្ម ស្ថាបត្យកម្ម ។ល។
- សិក្សាស្វែងយល់អំពីច្បាប់ ក្តាប់បានគោលនយោបាយ បទកំណត់ បទដ្ឋាននានារបស់រាជរដ្ឋាភិបាល ក្តាប់ និងប្រមូលផ្តុំព័ត៌មានស្តីពីសភាពការណ៍ សកម្មភាព ល្បិចកលនៃបទល្មើសដែលពាក់ព័ន្ធដល់ប្រតិបត្តិការគម្រោងវិស្វកម្ម ឬស្ថាបត្យកម្ម និងសកម្មភាពវិនិយោគមិនស្របតាមគោលការណ៍ ឬលក្ខន្តិកៈ ដែលរដ្ឋ ឬស្ថាប័ននីតិបុគ្គលសាធារណៈបានកំណត់ ដើម្បីលើកផែនការ វិធានការ បង្ការ តស៊ូប្រឆាំងនឹងបទល្មើសទាំងនោះ ។
- សហការជាមួយការិយាល័យជំនាញចំណុះនាយកដ្ឋាន ដើម្បីរួមគ្នាវិភាគពិចារណាស្វែងរកមូលហេតុធ្វើឱ្យកើតមានឡើងនូវឥទ្ធិពលអវិជ្ជមាន ដែលបង្កឱ្យមានការប៉ះពាល់ដល់ស្ថេរភាពទីផ្សារ និងសេដ្ឋកិច្ចជាតិ ធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ ឬក៏ប៉ះពាល់ដល់ផលប្រយោជន៍ប្រជាពលរដ្ឋ និងសង្គមដែលបណ្តាលមកពីភាពមិនប្រក្រតីនៃសកម្មភាពប្រតិបត្តិការគម្រោង វិស្វកម្ម ស្ថាបត្យកម្ម និងវិនិយោគ ដើម្បីលើកយោបល់ជូនថ្នាក់ដឹកនាំតាមលំដាប់ថ្នាក់ មានវិធានការដោះស្រាយទាន់ពេលវេលា ។
- ចាត់តាំង តាមដាន ត្រួតពិនិត្យ បម្រើឱ្យការងារជំនាញជាមូលដ្ឋានគ្រឹះ ដូចជាការងារស្រាវជ្រាវជាមូលដ្ឋាន ការស្រាវជ្រាវករណីសង្ស័យ ការកសាងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ការប្រើប្រាស់ជំនាញស៊ើបការបច្ចេក-ទេស ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសពាក់ព័ន្ធដល់វិស័យវិស្វកម្ម ស្ថាបត្យកម្ម និងវិនិយោគ ។
- ស្រាវជ្រាវ ស៊ើបអង្កេត ប្រមូលផ្តុំព័ត៌មាន និងឯកសារ ដើម្បីកំណត់គោលដៅ មុខសញ្ញាសង្ស័យ និងប្រមូលផ្តុំភស្តុតាង កសាងសំណុំរឿងតាមនីតិវិធីបញ្ជូនទៅតុលាការវិនិច្ឆ័យតាមច្បាប់ ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូននាយកដ្ឋានតាមការកំណត់ ។
- បំពេញភារកិច្ចផ្សេង១ទៀត ដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ ។

**៥-៧. ការិយាល័យការពារតម្លៃ បរិមាណ និងគុណភាព (ក៧) មានភារកិច្ច :**

- ធ្វើសេនាធិការជូនប្រធាននាយកដ្ឋាន ក្នុងការពិចារណាលើកផែនការ វិធានការស្រាវជ្រាវ បង្ការទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពដែលបង្កើតឱ្យមានវិសមភាពនៃតម្លៃទំនិញលើទីផ្សារ ការធ្វើសន្និធិខុសច្បាប់ ការធ្វើចរាចរទំនិញនៅលើទីផ្សារដែលមានបរិមាណមិនត្រឹមត្រូវតាមខ្នាតរង្វាស់រង្វាល់ ឬរង្វាស់ឧបករណ៍ និងទំនិញខូចគុណភាព ឬទំនិញហាមឃាត់ ។ល។ សំដៅធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការពារគោល-នយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ការពារផលប្រយោជន៍ និងសុខុមាលភាពអ្នកប្រើប្រាស់ ។

- សិក្សាស្វែងយល់អំពីច្បាប់ ក្តាប់បានគោលនយោបាយ បទកំណត់ បទដ្ឋាននានារបស់រាជរដ្ឋាភិបាលដែល ពាក់ព័ន្ធដល់ការគ្រប់គ្រង ត្រួតពិនិត្យតម្លៃលើទីផ្សារ (ទាំងតម្លៃទំនិញ និងអត្រាប្តូរប្រាក់) និងរួម សហការជាមួយការិយាល័យការពារសន្តិសុខសេដ្ឋកិច្ចជាតិ ដើម្បីធ្វើការពិចារណាលើក្រិត្យក្រមតម្លៃ វិភាគវាយតម្លៃលើការប្រែប្រួលនៃអត្រាប្តូរប្រាក់ និងបញ្ហាអតិផរណា សំដៅស្វែងរកឃើញមូលហេតុ នៃបាតុភាពអវិជ្ជមាន ដែលបង្កផលប៉ះពាល់ដល់ស្ថេរភាពនៃតម្លៃលើទីផ្សារ ដើម្បីលើកយោបល់ជូន ថ្នាក់ដឹកនាំតាមលំដាប់ថ្នាក់ សំដៅចាត់វិធានការដោះស្រាយបាតុភាពទាំងនោះទាន់ពេលវេលា ។
- សិក្សាស្វែងយល់អំពីច្បាប់ គោលនយោបាយ បទកំណត់ បទដ្ឋាននានារបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធ ដល់ការគ្រប់គ្រងត្រួតពិនិត្យលើបរិមាណ និងគុណភាពទំនិញ ដើម្បីធ្វើការតាមដានរាល់សកម្មភាពនៃ ការចរាចរទំនិញលើទីផ្សារ និងស្នើសុំគោលការណ៍ពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ លើកឡើងនូវវិធានការ សហការជាមួយស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ធ្វើការត្រួតពិនិត្យបង្ការទប់ស្កាត់ និងក្នុងករណី ចាំបាច់ត្រូវលើកវិធានការសហការបង្ក្រាប ដោយអនុលោមទៅតាមច្បាប់ និងនីតិវិធី ។
- សហការជាមួយការិយាល័យការពារសន្តិសុខសេដ្ឋកិច្ចជាតិ ដើម្បីសិក្សាស្វែងយល់អំពីច្បាប់ គោលនយោ- បាយ បទកំណត់ បទដ្ឋានរបស់រាជរដ្ឋាភិបាល និងទ្រឹស្តី បទដ្ឋាន លក្ខខណ្ឌនានា ដែលពាក់ព័ន្ធដល់សកម្ម- ភាពនៃកិច្ចដំណើរការផ្សារភាគហ៊ុន ផ្សារសញ្ញាប័ណ្ណ សំដៅលើកឡើងនូវវិធានការជំនាញចូលរួមការពារ ផលប្រយោជន៍វិនិយោគិន និងផលប្រយោជន៍អតិថិជនដែលធ្វើសេវាកម្មលក់-ទិញប័ណ្ណភាគហ៊ុន សញ្ញាប័ណ្ណ និងចូលរួមការពារ ទប់ស្កាត់រាល់សកម្មភាពដែលឆ្លៀតប្រើប្រាស់ទីផ្សារភាគហ៊ុន ឬទីផ្សារ សញ្ញាប័ណ្ណធ្វើជាឧបករណ៍បង្កអស្ថេរភាពដល់កិច្ចដំណើរការរបស់ម៉ាក្រូសេដ្ឋកិច្ច ។
- ចាត់តាំង តាមដាន ត្រួតពិនិត្យបម្រើឱ្យការងារជំនាញជាមូលដ្ឋានគ្រឹះ ដូចជាការងារស្រាវជ្រាវជាមូលដ្ឋាន ការស្រាវជ្រាវករណីសង្ស័យ ការកសាងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ការប្រើប្រាស់ជំនាញស៊ើបការបច្ចេកទេស ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើស ។
- ស្រាវជ្រាវ ស៊ើបអង្កេត ប្រមូលផ្តុំព័ត៌មាន និងឯកសារ ដើម្បីកំណត់គោលដៅ ឬមុខសញ្ញាសង្ស័យ និង ប្រមូលភស្តុតាងចងក្រងសំណុំរឿងតាមនីតិវិធីបញ្ជូនទៅតុលាការវិនិច្ឆ័យតាមច្បាប់ ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូននាយកដ្ឋានតាមការកំណត់ ។
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ ។

**៥-៨. ការិយាល័យការពារ ធនធានធម្មជាតិ បរិស្ថាន និងសុខុមាលភាព (ក៨) មានភារកិច្ច :**

- ធ្វើសេនាធិការជូនប្រធាននាយកដ្ឋាន ក្នុងការពិចារណាលើកផែនការ វិធានការតស៊ូប្រឆាំងបទល្មើសដែល បង្កមហន្តរាយដល់ធនធានធម្មជាតិ បរិស្ថាន និងបង្កគ្រោះថ្នាក់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ដោយគិតទាំងអាជីវកម្ម និងសេវាកម្មនានាដែលពាក់ព័ន្ធដល់វិស័យសុខាភិបាល ។
- សិក្សាស្វែងយល់អំពីច្បាប់ គោលនយោបាយ បទកំណត់ បទដ្ឋាននានារបស់រាជរដ្ឋាភិបាល និងរបស់ស្ថាប័ន នីតិបុគ្គលសាធារណៈ ព្រមទាំងធ្វើការស្រាវជ្រាវ ប្រមូលផ្តុំសភាពការណ៍រាល់សកម្មភាព ល្បិចកលនៃ បទល្មើស ដែលបំផ្លិចបំផ្លាញធនធានធម្មជាតិ បរិស្ថាន និងបង្កគ្រោះថ្នាក់ដល់សុខុមាលភាពប្រជាពលរដ្ឋ ទូទៅដើម្បីធ្វើជាមូលដ្ឋានពិចារណាលើកផែនការ វិធានការតស៊ូប្រឆាំងនឹងបទល្មើសទាំងនោះ សំដៅចូល រួមចំណែកការពារគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងសុខុមាលភាពប្រជាពលរដ្ឋ ។
- ចាត់តាំង តាមដាន ត្រួតពិនិត្យ បម្រើឱ្យការងារជំនាញជាមូលដ្ឋានគ្រឹះ ដូចជាការងារស្រាវជ្រាវជាមូលដ្ឋាន ការស្រាវជ្រាវករណីសង្ស័យ ការកសាងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ការប្រើប្រាស់ជំនាញស៊ើបការបច្ចេកទេស ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងធនធានធម្មជាតិ បរិស្ថាន និងសុខុមាលភាព ។

- ស្រាវជ្រាវ ស៊ើបអង្កេត វាយតម្លៃលើវិសាលភាពនៃការបង្កឱ្យមានហានិភ័យដល់ធនធានធម្មជាតិ បរិស្ថាន និងទំហំនៃការបង្កគ្រោះថ្នាក់ដល់សុខុមាលភាពសាធារណៈ ធ្វើការកំណត់មុខសញ្ញា ព្រមទាំងប្រមូលផ្តុំភស្តុតាង ដើម្បីកសាងសំណុំរឿងតាមនីតិវិធីបញ្ជូនទៅតុលាការវិនិច្ឆ័យតាមច្បាប់ ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូននាយកដ្ឋានតាមការកំណត់ ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ ។

**ប្រការ ៦ :** ការិយាល័យនីមួយៗ ដឹកនាំដោយនាយការិយាល័យ ០១ នាក់ និងមាននាយរងការិយាល័យចំនួន ០៤ នាក់ជាជំនួយ ។

**ប្រការ ៧ :** ចំនួនក្របខ័ណ្ឌមន្ត្រីនគរបាលជាតិចំណុះការិយាល័យនីមួយៗ អាស្រ័យដោយប្រធាននាយកដ្ឋានប្រឆាំងបទល្មើសសេដ្ឋកិច្ចពិភាក្សាឯកភាពជាមួយប្រធាននាយកដ្ឋានបុគ្គលិក ស្នើឡើងអគ្គស្នងការដ្ឋាននគរបាលជាតិ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យសម្រេច ។

**ប្រការ ៨ :** ភារកិច្ច និងរចនាសម្ព័ន្ធរបស់ផ្នែកចំណុះការិយាល័យ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គស្នងការដ្ឋាន-នគរបាលជាតិ ។

**ប្រការ ៩ :** ទំនាក់ទំនងការងារ
- រវាងការិយាល័យចំណុះនាយកដ្ឋាន ជាទំនាក់ទំនងសហការជួយឧបត្ថម្ភគ្នា ដើម្បីសម្រេចភារកិច្ចរបស់នាយកដ្ឋាន ។
- រវាងអង្គភាព នាយកដ្ឋានក្រោមឱវាទក្រសួងមហាផ្ទៃ ជាទំនាក់ទំនងសហការគ្នា ដើម្បីសម្រេចភារកិច្ចដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់ឱ្យ ។
- រវាងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ជាទំនាក់ទំនងតាមជានត្រួតពិនិត្យណែនាំមុខជំនាញ ដើម្បីសម្រេចភារកិច្ច ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**ប្រការ ១០ :** ខ្ទឹមសារដែលមានកំណត់តាមប្រកាសលេខ ០៩៥ ប្រ.ក ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១ :** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ប្រធានយកដ្ឋានកណ្តាល-មធ្យោបាយ ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ប្រធាននាយកដ្ឋាន-អង្គភាពដែលពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

<u>កន្លែងទទួល</u> ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចប្រការ ១១ (ដើម្បីអនុវត្ត)
- កាលប្បវត្តិ - ឯកសារ